# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការសំរបសំរួលផ្លូវជាតិលេខ ៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការសំរបសំរួលផ្លូវជាតិលេខ ៧ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **សេខ ឈឹមនៅ** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម | **ញាណ ឡេង** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម | **អ៊ុក ចាន់** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៤- លោក | **អ៊ុំ សារូ** | អគ្គនាយករងរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- លោក | **ខាំ គឿន** | អភិបាលរងទី ២ ខេត្តក្រចេះ | សមាជិក |
| ៦- លោក | **មួង ម៉ិយ** | អភិបាលរងទី ២ ខេត្តរតនគិរី | សមាជិក |
| ៧- លោក | **ឆាំង ឃាងសាន** | អភិបាលរងទី ៣ ខេត្តស្ទឹងត្រែង | សមាជិក |
| ៨- បណ្ឌិត | **ជា វ៉ាន់ដេត** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ គ.រ.ម | សមាជិក |

**ប្រការ២ :** គណៈកម្មការមានភារកិច្ចសហការជាមួយស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន និងក្រុមហ៊ុនចិន ក្នុងការសំរបសំរួល និងក្នុងការដោះស្រាយលំនៅដ្ឋានតាមបណ្តោយផ្លូវជាតិលេខ ៧ និងពិនិត្យដោះស្រាយបញ្ហាផ្សេងៗ ដែលអាចកើតមានក្នុងពេលក្រុមហ៊ុនអនុវត្តគំរោង ។

**ប្រការ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ